ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៤ អយក.សព្រ៧

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី
# ការប្រារព្ធសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៤-២០២៥ និងទិសដៅឆ្នាំសិក្សា ២០២៥-២០២៦

ក្រសួងអប់រំ យុវជន និងកីឡាសូមជម្រាបជូនបុគ្គលិកអប់រំ និងសាធារណជនមេត្តាជ្រាបថា៖ ក្រសួងនឹងរៀបចំសន្និបាតបូកសរុបលទ្ធផលការងារអប់រំ យុវជន និងកីឡា ឆ្នាំសិក្សា ២០២៤-២០២៥ និងទិសដៅឆ្នាំសិក្សា ២០២៥-២០២៦ រយៈពេលបីថ្ងៃ ចាប់ផ្តើមពីថ្ងៃទី១១ ដល់ថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០២៦ នៅវិទ្យាស្ថានបច្ចេកវិទ្យាកម្ពុជា ដោយមានចូលរួមពីថ្នាក់ដឹកនាំក្រសួងអប់រំ យុវជន និងកីឡាគ្រប់លំដាប់ថ្នាក់ គ្រឹះស្ថានបណ្តុះបណ្តាលគ្រូ តំណាងក្រសួង ស្ថាប័នពាក់ព័ន្ធ ប្រតិភូមន្ទីរអប់រំ យុវជន និងកីឡារាជធានី-ខេត្ត គណៈអភិបាលរាជធានី-ខេត្ត ប្រធានក្រុមប្រឹក្សា រាជធានី-ខេត្ត រដ្ឋបាលក្រុង ស្រុក ខណ្ឌ ការិយាល័យអប់រំ យុវជន និងកីឡាក្រុង ស្រុក ខណ្ឌ ដៃគូអភិវឌ្ឍ អង្គការជាតិ-អន្តរជាតិ សមាគមគ្រឹះស្ថានឧត្តមសិក្សា និងអង្គការ មិនមែនរដ្ឋាភិបាល ក្នុងនោះអ្នកចូលរួមដោយផ្ទាល់ប្រមាណ ២.០០០នាក់ ព្រមទាំងការផ្សាយផ្ទាល់តាមរយៈបណ្តាញសង្គមហ្វេសប៊ុក (Facebook) ផ្លូវការរបស់ក្រសួងអប់រំ យុវជន និងកីឡា។

អង្គសន្និបាតនេះ រៀបចំឡើងក្នុងគោលបំណងពិនិត្យមើលឡើងវិញរួមគ្នាស្តីពី វឌ្ឍនភាពរបស់វិស័យអប់រំ យុវជន និងកីឡាដែលសម្រេចបានក្នុងឆ្នាំកន្លងទៅ និងលើកទិសដៅការងារសម្រាប់ឆ្នាំបន្ទាប់។

អង្គសន្និបាតនឹងប្រារព្ធពិធីបើក និងបិទ ក្រោមអធិបតីភាព ឯកឧត្តមបណ្ឌិតសភាចារ្យ **ហង់ជួន ណារ៉ុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម បុគ្គលិកអប់រំ និងសាធារណជនទាំងអស់ ជ្រាបជាព័ត៌មាន និងចូលរួមតាមដាន ព្រមទាំងចែករំលែកការផ្សាយផ្ទាល់នៃដំណើរការអង្គសន្និបាតនេះឱ្យបានទូលំទូលាយ។

ថ្ងៃអង្គារ ៨ រោច ខែមាឃ ឆ្នាំម្សាញ់ សប្តស័ក ព.ស. ២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០២៦

អាសយដ្ឋាន៖ អគារលេខ ៨០ មហាវិថីព្រះនរោត្តម រាជធានីភ្នំពេញ កម្ពុជា
info@moeys.gov.kh / administration@moeys.gov.kh
ទូរស័ព្ទ៖ (+៨៥៥) ២៣ ២២០ ៦៧៣ / ២២០ ៣០៤
www.moeys.gov.kh